# ព្រះរាជក្រឹត្យ

នស/រកត/១២១៤/១៤៤៥

## ស្តីពី

## ការកែសម្រួលមាត្រា៤ មាត្រា៥ និងមាត្រា៧នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានសំបូរព្រៃគុក

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងគ្រប់គ្រងធនធានធម្មជាតិ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានសំបូរព្រៃគុក
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ.-**

មាត្រា៤ មាត្រា៥ និងមាត្រា៧នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការកំណត់រមណីយដ្ឋានសំបូរព្រៃគុក ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា៤ថ្មី.-**

រមណីយដ្ឋានការពារប្រាសាទសំបូរព្រៃគុក ត្រូវចាត់ជា៣(បី)តំបន់ផ្សេងៗគ្នា ហើយត្រូវទទួលកម្រិតការពារខុសៗគ្នា៖

១- **តំបន់ស្នូល** : តំបន់មានប្រាសាទសំខាន់ជាងគេនិងជាតំបន់ឧទ្យានប្រាសាទតូចធំ រួមទាំងសម្បត្តិវប្បធម៌ បុរាណវិទ្យា ព្រមទាំងវត្ថុតាងជាច្រើនទៀត ដែលមានរូបរាងនៅលើដីឬកប់ក្នុងដីកំពុងស្រាវជ្រាវឬពុំទាន់ស្រាវជ្រាវរកឃើញដោយអ្នកបុរាណវិទ្យា ហើយត្រូវទទួលកិច្ចការពារកម្រិតខ្ពស់បំផុត។

តំបន់នេះមានផ្ទៃក្រឡាសរុប ១ ៣៥៤,២៦ហិកតា ដែលមានកំណត់ក្នុងនិយាមកាដូចខាងក្រោម៖

| | | |
|---|---|---|
| $A_1$ (503211, 1425262) | , | $B_1$ (502904, 1424858) |
| C1 (502873, 1423171) | , | $D_1$ (501557, 1423004) |
| $E_1$ (502045, 1420962) | , | $F_1$ (504536, 1421428) |
| $G_1$ (504380, 1421102) | , | $H_1$ (504310, 1420606) |
| $I_1$ (504355, 1420592) | , | $J_1$ (504462, 1420736) |
| $K_1$ (504680, 1421187) | , | $L_1$ (504773, 1421665) |
| $M_1$ (505094, 1421665) | , | $N_1$ (505224, 1421950) |
| $O_1$ (507688, 1422128) | , | $P_1$ (507571, 1422534) |
| $Q_1$ (504458, 1424288) | , | $R_1$ (504613, 1425289) |

២- តំបន់ទ្រនាប់ : តំបន់សម្បូរដោយសំណល់បុរាណវត្ថុ និងជាឧទ្យានបុរាណវត្ថុដែលមានបន្សល់ទុកនូវស្លាកស្នាមកប់ក្នុងដីរាក់ឬជ្រៅ ហើយពុំទាន់រុករកឃើញដោយអ្នកបុរាណវិទ្យា នៅតាមទីវាល ផ្ទៃដី ឬក្នុងភូមិ ឃុំ ក្រោមផ្ទះប្រជាជនជាដើម ដែលត្រូវការពារ ទប់ស្កាត់នឹងការប្រើប្រាស់ដីធ្លីនិងការអភិវឌ្ឍមិនសមស្រប។

តំបន់នេះ មានផ្ទៃក្រឡា២ ០០៩,៣០ហិកតា ដែលមានកំណត់ក្នុងនិយាមកាដូចខាងក្រោម៖

| | | |
|---|---|---|
| A (502721; 1426711) | , | B (501633; 1425998) |
| C (500537; 1423348) | , | D (501733; 1418978) |
| E (504456; 1420172) | , | F (505480; 1420622) |
| G (505567; 1421717) | , | H (508911; 1421701) |
| I (508909; 1422487) | , | J (505583; 1424066) |
| K (505604; 1425246) | | |

៣- តំបន់រណប : តំបន់អភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច ដោយរក្សាជីវភាព មុខរបរ អាជីវកម្មតាមទំនៀមទម្លាប់ ប្រពៃណី ព្រមទាំងការរស់នៅរបស់ប្រជាជនក្នុងតំបន់។ តំបន់នេះស្ថិតនៅក្រៅពីបរិវេណដែលមាននិយាមកាចំណុច A B C D E F G H I J K ចម្ងាយ១៥០០ម៉ែត្រ។

តំបន់នេះជាគោលដៅថែរក្សាបេតិកភណ្ឌវប្បធម៌និងធម្មជាតិ តាមរយៈការចាត់ចែងវិធានការដើម្បីជំរុញការអភិវឌ្ឍឲ្យមានចីរភាព និងមានការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន។

ប្លង់កំណត់តំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក មានភ្ជាប់ជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ។

**មាត្រា៥ថ្មី .-**

ការអភិរក្សរាល់តំបន់នីមួយៗ សុទ្ធតែត្រូវបានគ្រប់គ្រង ថែទាំ និងការពារ ស្របតាមទិសដៅចំណាត់ថ្នាក់តំបន់ដូចមានចែងក្នុងមាត្រា៤ថ្មីនៃព្រះរាជក្រឹត្យនេះ និងកម្រិតនៃសារៈសំខាន់ដោយឡែកៗទាំងខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា បរិស្ថាន ធម្មជាតិ គោរពនូវសិទ្ធិជាម្ចាស់របស់ប្រជាជនរស់នៅក្នុងតំបន់ទាំងមូល ខាងជីវភាពរស់នៅ និងលើកស្ទួយរមណីយដ្ឋានការពារឲ្យមានតម្លៃកាន់តែខ្ពស់ឡើង។

**មាត្រា៧ថ្មី .-**

បរិវេណនិងរាល់សកម្មភាពរបស់តំបន់នីមួយៗនៃរមណីយដ្ឋានការពារប្រាសាទសំបូរព្រៃគុក អាចពិនិត្យឡើងវិញហើយកែប្រែបាន ដោយផ្អែកលើរាល់លទ្ធផលនៃការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របុរាណវិទ្យានិងស្ថានភាពជាក់ស្តែង ដើម្បីធានាដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច ការអភិរក្ស និងការគ្រប់គ្រងមួយប្រកបដោយនិរន្តរភាព ដូចមានចែងក្នុងមាត្រា៤ថ្មី។

ការកែប្រែតំបន់និងរាល់សកម្មភាពពាក់ព័ន្ធនឹងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ត្រូវកំណត់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់រាជរដ្ឋាភិបាល។

**មាត្រាពីរ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី ._**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១៤

ពរស.១៤១២.១៥១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

**ហត្ថលេខា**

**ភឿង សកុណា**

លេខៈ ១៥០៥ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

ឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៨៨ .ចុះថ្ងៃទី ២៤..ខែ.. ធ្នូ .....ឆ្នាំ ២០១៤ ...ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក




បញ្ជាក់:ចំពោះការកាន់កាប់ដីក្នុងតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកទាំងមូលនឹងត្រូវធ្វើការសិក្សាដើម្បីកំណត់អំពីសិទ្ធិនិងវិធាននៃការប្រើប្រាស់ដីជាក្រោយ ។

| | |
|---|---|
| បានឃើញ និងឯកភាព | បានឃើញ និងឯកភាព |
| រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១៤ | រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៤ |
| ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| អ៊ឹម ឈុនលឹម | ភឿង សកុណា |